01363209

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារ D299/3/2

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ២៧)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 12 / 2016
ម៉ោង (Time/Heure): 13:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សាធារណៈ: (កោសលុប)

**សេចក្តីពិចារណាលើសំណើរបស់ [redacted] សុំអង្គបុរេជំនុំជម្រះ ទទួលពិចារណាលើការធ្វើមោឃភាព កិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញ្ញដី និងបទចោទនានាទាក់ទងនឹងទួលបេង**

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍</u>**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

អង្គបុរេជំនុំជម្រះ * ECCC * CETC * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើសុំអង្គបុរេជំនុំជម្រះទទួលពិចារណា លើការធ្វើមោឃភាពកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញ្ញជី និងបទចោទនានាទាក់ទងនឹងទួលបេង" ដែលបានដាក់ដោយសហមេធាវីការពារក្តី [redacted] ("មេធាវីការពារក្តី") កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ("សំណើសុំ")[1]។

## I. សេចក្តីផ្តើម

1. សំណើសុំត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជូនមកអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៦(៣) នៃវិធានផ្ទៃក្នុង ("សេចក្តីសម្រេចបញ្ជូនបន្ត")[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ មានការខ្វែងយោបល់មួយរវាង សហព្រះរាជអាជ្ញា លើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីចំនួនពីរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយ ត្រូវបានលើកយកមកចំពោះមុខ អង្គបុរេជំនុំជម្រះ[3] ។ សហព្រះរាជអាជ្ញាអន្តរជាតិ មានបំណងបញ្ជូនដីកាសន្និដ្ឋានទាំងនេះ ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ តែសហព្រះរាជអាជ្ញាជាតិជំទាស់។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះមិនអាចស្វែងរកមតិភាគច្រើនតាមការតម្រូវ សម្រាប់ចេញសេចក្តីសម្រេចលើ

---

[1] សំណើសុំអង្គបុរេជំនុំជម្រះទទួលពិចារណា លើការធ្វើមោឃភាពកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញ្ញជី និងបទចោទនានាទាក់ទងនឹងទួលបេង, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦, ឯកសារ D299។

[2] សេចក្តីសម្រេចលើសំណើរបស់ [redacted] សុំអង្គបុរេជំនុំជម្រះទទួលពិចារណា លើការធ្វើមោឃភាពកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញ្ញជី និងបទចោទនានាទាក់ទងនឹងទួលបេង, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦, ឯកសារ D299/1 ( "សេចក្តីសម្រេចបញ្ជូនបន្ត"), កថាខណ្ឌ ៣៧។ *សូមមើលផងដែរ* លិខិតរបស់ក្រឡាបញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមន្ត្រីទទួលបន្ទុកសំណុំរឿង ទាក់ទងការបញ្ជូនឯកសារក្នុងសំណុំរឿង ០០៤ ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមសំណុំរឿង ០០៤-D299, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦, ឯកសារ D299/3។

[3] សេចក្តីប្រកាសជាលាយលក្ខណ៍អក្សររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីអង្គហេតុនិងសំអាងហេតុ នៃការខ្វែងយោបល់គ្នា អនុលោមតាមវិធាន ៧១(២) នៃវិធានផ្ទៃក្នុង, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨, Doc. No. 1។

ការខ្វែងយោបល់គ្នា ហើយបានសន្និដ្ឋានជាឯកច្ឆន្ទថា អនុលោមតាមវិធាន ៧១(៤)(គ) "កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវអនុវត្ត"[4]។

3. នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយចោទប្រកាន់ [redacted] (ហៅ "[redacted]" និង "[redacted]") ពីការចូលរួមនៅក្នុងសកម្មភាពឧក្រិដ្ឋកម្ម[5]។ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងទីតាំងឧក្រិដ្ឋកម្មតំបន់១ និងការធ្វើទុក្ខបុកម្នេញខ្មែរក្រោម[6]។ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ ដើម្បីបញ្ជាក់បំភ្លឺថា "កិច្ចស៊ើបសួរដែលកំពុងធ្វើឡើងនៅទីតាំងឧក្រិដ្ឋកម្មភ្នំប្រុស និងគោកព្រីង ក្នុងស្រុកកំពង់សៀម ដូចបានរៀបរាប់ក្នុងកថាខណ្ឌ ៣០ ដល់៣៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី គឺមានបំណងដើម្បីដាក់បញ្ចូលមន្ទីរសន្តិសុខកំពង់សៀម ដែលមានទីតាំងស្ថិតនៅក្នុងវត្តអង្គញដី នៅក្នុងឃុំក្រឡា និងទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅក្នុងភូមិទួលបេង ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុង កំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេត កសចស" ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ")[7]។

4. នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ដើម្បីស្វែងរកការបញ្ជាក់បំភ្លឺពីសហព្រះរាជអាជ្ញា ថាតើទីតាំងទួលបេងស្ថិតក្នុងវិសាលភាព នៃកិច្ចស៊ើបសយរដែលត្រូវអនុវត្ត នៅក្នុងគោកព្រីង និងភ្នំប្រុស ដែរឬយ៉ាងណា ("ដីកាបញ្ជូន

[4] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង, ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, ឯកសារ D1/1.3, កថាខណ្ឌ ៤៥។

[5] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨, ឯកសារ D1, កថាខណ្ឌ ១១៧(គ)។ សូមមើលផងដែរ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីទី ស្តីពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី, ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩, ឯកសារ D1/1។

[6] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងទីតាំងឧក្រិដ្ឋកម្មតំបន់១ និងការធ្វើទុក្ខបុកម្នេញទៅលើខ្មែរក្រោម, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១, ឯកសារ D65។

[7] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងការរៀបការដោយបង្ខំ និងអំពើហិង្សាយេនឌ័រ, ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤, ឯកសារ D191, កថាខណ្ឌ ១១។

01363212



សំណុំរឿងទៅពិនិត្យ") [8] ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកត់សម្គាល់ថា ផ្ទុយពីការចោទប្រកាន់នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរនោះ ភស្តុតាងថ្មីៗបានបង្ហាញថា វត្តអង្គញជី មិនត្រូវបានគេកំណត់ជាផ្លូវការថាជាមន្ទីរសន្តិសុខឡើយ ហើយថាមន្ទីរសន្តិសុខរបស់ស្រុកកំពង់សៀម គឺស្ថិតនៅទីតាំងផ្សេងនៅក្នុងភូមិទួលបេង។ ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្នើសុំការបញ្ជាក់បំភ្លឺពីសហព្រះរាជអាជ្ញា ដោយកត់សម្គាល់ថាលទ្ធផលរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបន្តកិច្ចស៊ើបសួរលើទីតាំងទួលបេង ដែលមិនត្រឹមតែជាទីតាំងសម្លាប់មនុស្សប៉ុណ្ណោះទេ តែជាមន្ទីរសន្តិសុខផងដែរនោះ ព្រមជាមួយឧក្រិដ្ឋកម្មនានាដែលប្រហែលជាអាចប្រព្រឹត្តឡើងនៅវត្តអង្គញជី គឺអាស្រ័យទៅលើថាតើទីតាំងទួលបេងស្ថិតក្នុងវិសាលភាពនៃ កិច្ចស៊ើបសួរដែលលើកឡើងពីខាងលើដែរឬយ៉ាងណា [9] ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតកត់សម្គាល់ពីការប្រកាសកន្លងមក របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីដែលថា "យុត្តាធិការលើទីតាំងជាក់លាក់ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានពង្រីកហួសពីបរិវេណជាក់ស្តែង រហូតទៅដល់ទីតាំងពាក់ព័ន្ធនានា"[10]។

5. នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ចម្លើយតបចំពោះ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ដោយអះអាងថាទីតាំងទួលបេង ស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ("ចម្លើយតបចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")[11]។

6. នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ [redacted] ត្រូវបានកោះហៅមកបង្ហាញខ្លួនជាលើកដំបូង នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើមនុស្សឃាតដោយចេតនា ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត នៅមន្ទីរសន្តិសុខទួលបេង[12]។

---

[8] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ, ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥, ឯកសារ D237, ទំព័រ ៣។

[9] *ដូចដើងទំព័រខាងលើ។*

[10] *ដូចដើងទំព័រខាងលើ។*

[11] ចម្លើយតបចំពោះ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ (ឯកសារ D237), ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥, ឯកសារ D237/1, កថាខណ្ឌ ២។

[12] កំណត់ត្រានៃការបង្ហាញខ្លួនលើកដំបូង, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥, ឯកសារ D242, ទំព័រ ៦ ដល់៧។

7. នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ មេធាវីការពារក្ដីបានដាក់សំណើសុំអង្គបុរេជំនុំជម្រះ ធ្វើមោឃភាព កិច្ចស៊ើបសួរ ទាក់ទងទួលបេង និងវត្តអង្គញជី ដែលបានធ្វើឡើង៖ ១) ពីខែកុម្ភៈ ឆ្នាំ២០១២ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ នៅពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ ត្រូវបានដាក់ ដោយលើកទឡ្ហីករណ៍ថា ទីតាំងទាំងអស់ដែលកំពុងចោទជាបញ្ហា មិនមានរៀបរាប់នៅក្នុងកថាខណ្ឌ ២៣ ដល់៣៦ និងកថាខណ្ឌ ៤៩ ដល់៥៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[13] ២) បន្ទាប់ពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ និងរហូតដល់ការដាក់ចម្លើយតបចំពោះ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ដោយជំទាស់ថា ការបញ្ជាក់បំភ្លឺរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ គឺមិនគ្រប់គ្រាន់ក្នុងការបង្កើតជាការផ្ដល់សិទ្ធិ ក្នុងការពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ[14] និង ៣) ក្រោយថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ដោយសារចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី ចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ មិនអាចចាត់ទុកថាជា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមានសុពលភាព ចំពោះទីតាំងដែលចោទជាបញ្ហា[15]។ [redacted]បានស្នើសុំបន្ថែមដល់អង្គបុរេជំនុំជម្រះ ឱ្យធ្វើមោឃភាពបទចោទទាក់ទងទួលបេង ដោយសារតែបទចោទទាំងអស់នោះ ផ្អែកទៅលើកិច្ចស៊ើបអង្កេត ដែលមានកំហុសឆ្គងផ្នែកនីតិវិធី និងមិនបានទទួលការអនុញ្ញាត[16]។

8. នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកោះហៅឱ្យបង្ហាញខ្លួនម្ដងទៀត ដែលពេលនោះគាត់បានជូនដំណឹងដល់ [redacted] ថា មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាដែលបង្ហាញថា [redacted] អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលមានយោងនៅក្នុងដីកាសន្និដ្ឋាន នៅតាមទីតាំងមួយចំនួនដូចជា មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ទួលបេង និងវត្តអង្គញជី[17]។

---

[13] សំណើសុំ, កថាខណ្ឌ ៤១ ដល់៤៣។

[14] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៥។

[15] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៨ ដល់៥៣។

[16] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៥៤ ដល់៥៥។

[17] កំណត់ត្រានៃការបង្ហាញខ្លួនម្ដងទៀត, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦, ឯកសារ D303, ទំព័រ ៣, ៥, ៦ និង៨។

9. នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ សេចក្តីសម្រេចបញ្ជូនបន្ត ដោយអនុញ្ញាតតាមសំណើសុំ ត្រឹមចំណុចដែលសំណើសុំនេះទាក់ទងជាមួយ សំណើសុំមោឃភាពលើកិច្ចស៊ើបសួរ ដែលធ្វើឡើងក្នុងអំឡុងពេលពីខែកុម្ភៈ ឆ្នាំ២០១២ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ហើយបដិសេធផ្នែកដែលនៅសល់ នៅក្នុងសំណើសុំនេះ[18]។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាឱ្យក្រឡាបញ្ជីបញ្ជូនសំណុំរឿង ០០៤ ទៅអង្គបុរេជំនុំជម្រះ ដើម្បីឱ្យធ្វើការត្រួតពិនិត្យលើ សំណុំសុំដែលបានបញ្ជូនបន្ត[19]។

10. នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ អង្គបុរេជំនុំជម្រះបានចេញការណែនាំដល់ភាគី ដែលត្រូវបានជូនដំណឹងតាមរយៈសារអេឡិចត្រូនិក របស់មន្ត្រីគ្រប់គ្រងសំណុំរឿង ដោយបញ្ជាដល់មេធាវីការពារក្តី [redacted] ថាត្រូវតែដាក់សំណើសុំនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងរយៈពេល១០ថ្ងៃគិតចាប់ពីពេលជូនដំណឹង ហើយប្រសិនបើសំណើសុំមិនត្រូវបានដាក់ នៅចំពោះមុខអង្គបុរេជំនុំជម្រះតាមកាលបរិច្ឆេទកំណត់នេះទេ អង្គបុរេជំនុំជម្រះនឹងទទួលយកសំណើសុំ ដូចដែលបានដាក់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត[20]។ មិនមានសំណើសុំណាមួយត្រូវបានដាក់ នៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមកាលបរិច្ឆេទកំណត់ឡើយ។

11. នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបចំពោះសំណើសុំ ដោយស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យច្រានចោលសំណើសុំនេះ ដោយសារតែមិនមានមូលដ្ឋាន ព្រោះមិនមានកំហុសឆ្គងនីតិវិធី ឬមិនមានការរំលោភបំពាន ទៅលើសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌របស់ [redacted] ឡើយ ហើយសហព្រះរាជអាជ្ញាបានលើកឡើងថា បើទោះបីជាមានការ

---

[18] សេចក្តីសម្រេចបញ្ជូនបន្ត, កថាខណ្ឌ ៣៧ ដល់៣៨។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចបញ្ជូនបន្ត។

[19] លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ទៅកាន់មន្ត្រីទទួលបន្ទុកសំណុំរឿង អំពីការបញ្ជូនសំណុំរឿងលេខ០០៤ ទៅអង្គបុរេជំនុំជម្រះអនុលោមទៅតាម សំណុំរឿង០០៤-D299/1, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦, ឯកសារ D299/3។

[20] ការជូនដំណឹងរបស់មន្ត្រីទទួលបន្ទុកសំណុំរឿង, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦, ការបង្គាប់របស់អង្គបុរេជំនុំជម្រះ ចំពោះភាគីនៃសំណុំរឿង ០០៤/០៧-០៩-២០០៩- អវតក/កសចស (អបជ ២៧)។

រំលោភបំពានក៏ដោយ ក៏ការធ្វើមោឃភាពមិនមែនជាការជួសជុលសងដែលសមស្របនោះឡើយ ("ចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា")[21]។

12. មេធាវីការពារក្តីមិនបានដាក់ការឆ្លើយតប តាមកាលបរិច្ឆេទកំណត់តាមផ្លូវច្បាប់ឡើយ។

## III. ទិសាលភាពនៃការពិចារណារបស់ អង្គបុរេជំនុំជម្រះ

13. អង្គបុរេជំនុំជម្រះត្រូវត្រួតពិនិត្យតែចំពោះ លទ្ធផលនៃកិច្ចស៊ើបសួរទាក់ទងទួលបេង និងវត្តអង្គញជី ដែលធ្វើឡើងក្នុងអំឡុងពេលពីខែកុម្ភៈ ឆ្នាំ២០១២ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ តែប៉ុណ្ណោះ ("កិច្ចស៊ើបសួរដែលរងការជំទាស់") ដោយសារសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធ និងមិនបញ្ជូនបន្ត ផ្នែកដែលនៅសល់នៅក្នុងសំណើសុំ មកអង្គបុរេជំនុំជម្រះ[22] ហើយមិនមានការដាក់បណ្តឹងឧទ្ធរណ៍ ប្រឆាំងសេចក្តីសម្រេចបដិសេធរបស់ ការិយាល័យសហចៅក្រមស៊ើបអង្កេត។

14. ការធ្វើមោឃភាពអាចប្រមើលមើលបាន តាមវិធាន ៤៨ នៃវិធានផ្ទៃក្នុងដែលចែងថា "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ របស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"។ ហេតុដូច្នេះភាពមិនប្រក្រតីផ្នែកនីតិវិធី ដែលមិនបណ្តាលឱ្យប៉ះពាល់ដល់អ្នកដាក់ពាក្យសុំ នឹងមិននាំដល់ការធ្វើមោឃភាពឡើយ[23]។

---

[21] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះសំណើរបស់ [redacted] សុំមោឃភាពកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានាទាក់ទងនឹងទួលបេង, ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦, ឯកសារ D299/3/1។

[22] សេចក្តីសម្រេចបញ្ជូនបន្ត, កថាខណ្ឌ ៣៧ ដល់៣៨។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ក នៃសេចក្តីសម្រេចបញ្ជូនបន្ត។

[23] សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") (អបជ ២០), សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរ សុំមោឃភាពកិច្ចស៊ើបសួរ, ឯកសារ D134/1/10, ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ទាក់ទងសំណើចំនួនពីរ"), កថាខណ្ឌ ២៦ យោងទៅរក សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២")(អបជ ៤១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យ អង្គបុរេជំនុំជម្រះ

15. វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុងចែងបន្ថែមថា "នៅពេលអង្គបុរេជំនុំជម្រះសម្រេចទុកជាមោឃៈកិច្ចស៊ើបសួរណាមួយ អង្គបុរេជំនុំជម្រះត្រូវសម្រេចថា តើមោឃភាពនោះមានប៉ះពាល់ដល់កិច្ច ឬដីកាដទៃទៀតដែរឬទេ"។ នៅពេលកំណត់បានពីព្យសនកម្ម ដំណាក់កាលចុងក្រោយគឺពាក់ព័ន្ធ ការកំណត់ពីផ្នែកនៃកិច្ចដំណើរការនីតិវិធី ដែលត្រូវធ្វើមោឃភាព។ ក្នុងករណីធាតុផ្សំមួយក្នុងចំណោមធាតុផ្សំស្រុបទាំងបី មិនអាចត្រូវបានកំណត់ ការធ្វើមោឃភាពមិនអាចបន្តបាន ហើយការវាយតម្លៃបន្តនឹងមិនចាំបាច់ត្រូវធ្វើឡើងឡើយ។ ហេតុដូច្នេះអង្គបុរេជំនុំជម្រះនឹងពិចារណា ថាតើការចោទប្រកាន់ទាក់ទងទួលបេង មានកំហុសនីតិវិធីដែរឬយ៉ាងណា តែក្នុងករណីដែលអង្គបុរេជំនុំជម្រះសម្រេចថា កិច្ចស៊ើបអង្កេតនោះត្រូវធ្វើមោឃភាពប៉ុណ្ណោះ។

## IV. ភាពអាចទទួលយកបាន

16. វិធាន ៧៦(៤) នៃវិធានផ្ទៃក្នុងបង្គាប់ថា អង្គបុរេជំនុំជម្រះអាចប្រកាសថា សំណើសុំមោឃភាពមួយមិនអាចទទួលយកបាន ក្នុងករណីដែលសំណើសុំនោះ៖ ១) មិនបានបង្ហាញហេតុផលគ្រប់គ្រាន់ ២) មានពាក់ព័ន្ធជាមួយដីកាដែលត្រូវប្តឹងឧទ្ធរណ៍ ឬ ៣) ពាក្យសុំនេះគ្មានមូលដ្ឋានច្បាស់លាស់។ ហេតុដូច្នេះអង្គបុរេជំនុំជម្រះត្រូវស្វែងរកថាតើ សំណើសុំមោឃភាព៖ ១) បញ្ជាក់ច្បាស់លាស់ផ្នែកនៃកិច្ចដំណើរការនីតិវិធី ដែលប៉ះពាល់ដល់សិទ្ធិនិងផលប្រយោជន៍ របស់ម្ចាស់សំណើ

ធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1), ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០, ឯកសារ D263/2/6, ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ"), កថាខណ្ឌ ២១។

សុំ[24] ២) បានបង្ហាញច្បាស់លាស់ពីព្យសនកម្ម[25] និង៣) ក្នុងករណីចាំបាច់ បានបង្ហាញភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រការចោទប្រកាន់[26]។

17. អង្គបុរេជំនុំជម្រះជឿជាក់ថា លក្ខខណ្ឌនៃវិធាន ៧៦(៤) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ។ បទចោទ និងកិច្ចស៊ើបសួរដែលត្រូវបានជំទាស់[27] មិនពាក់ព័ន្ធដីកាដែលត្រូវប្ដឹងឧទ្ធរណ៍ តាមវិធានផ្ទៃក្នុងឡើយ។ គ្មានចំណុចណាមួយនៅក្នុងសំណើសុំបង្ហាញថា សំណើសុំមិនមានមូលដ្ឋានទាំងលើអង្គហេតុ ឬអង្គច្បាប់ ដែលធ្វើឱ្យសំណើនេះមិនអាចមានលទ្ធភាព ទទួលបានជោគជ័យ។ អង្គបុរេជំនុំជម្រះយល់ឃើញបន្ថែមថា សំអាងហេតុដែលមាននៅក្នុងសំណើសុំ គឺគ្រប់គ្រាន់ដោយសារសំណើសុំនេះមានសារណាដែលស៊ីសង្វាក់គ្នាសមស្រប ហើយគាំទ្រដោយសំអាងហេតុផ្លូវច្បាប់ ដែលមូលដ្ឋាននៃសំអាងហេតុផ្លូវច្បាប់នេះ ត្រូវបានលើកឡើងច្បាស់ ឬគាំទ្រដោយសម្ភារៈអង្គហេតុ ដែលបានចង្អុលបង្ហាញនៅក្នុងសំណុំរឿង។

18. ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេចថា សំណើសុំនេះអាចទទួលយកបាន។

## V. ការពិចារណាលើអង្គសេចក្តី

---

[24] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ២៤ ("ហេតុដូច្នេះការធ្វើមោឃភាពត្រូវតែបញ្ជាក់... ឱ្យបានជាក់លាក់ថាតើកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះណាមួយ ដែលមានកំហុសនីតិវិធី...")។

[25] *សូមមើល* សំណុំរឿង ០០២ (អបជ ០៦), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព,ឯកសារ D55/I/8, ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា"), កថាខណ្ឌ ៤០ ("ការបង្ហាញអំពីការរំលោភសិទ្ធិ ... ដែលត្រូវបានទទួលស្គាល់នៅក្នុង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចបង្គ្រប់ជាកំហុសនីតិវិធី...។ នៅក្នុងករណីបែបនេះ កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការ អាចចាត់ទុកថាមោឃៈ""), និងកថាខណ្ឌ ៤២ ("[នៅក្នុងករណីផ្សេងទៀត] ភាគីដែលដាក់ពាក្យសុំ នឹងត្រូវបង្ហាញថា ផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយសារកំហុសនីតិវិធី")។

[26] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, កថាខណ្ឌ ៣២។

[27] *សូមមើល* សំណុំរឿង ០០៣/07-09-2009-អវតក/កសចស ("សំណុំរឿង ០០៣") (អបជ ២៩), សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ [redacted] ឱ្យស្ថិតក្រោមការត្រួតពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរ នៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ, ឯកសារ D174/1/4, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦។

19. បន្ទាប់ពីពិភាក្សារួចមក ចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកបានមតិភាគច្រើនដើម្បីធ្វើសេចក្តីសម្រេចទៅលើអង្គសេចក្តីនៃសំណើនេះបានឡើយ។

20. ដូច្នេះ ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះភាពអាចទទួលយកបាននៃសំណើនេះមានបញ្ជាក់នៅក្នុងកថាខណ្ឌខាងមុខយ៉ាងណាក៏ដោយ ក៏មានការភ្ជាប់បន្ថែមមកជាមួយយោបល់ដាច់ដោយឡែករបស់ចៅក្រមនានានៃអង្គបុរេជំនុំជម្រះ ទាក់ទិននឹងអង្គសេចក្តីនៃសំណើនេះ តាមលក្ខខណ្ឌតម្រូវនៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង។

## សេចក្តីសម្រេច

ដោយផ្អែកលើហេតុផលទាំងនេះ អង្គបុរេជំនុំជម្រះយោងតាមសំឡេងឯកច្ឆន្ទ៖

១. យល់ឃើញថាពាក្យសុំនេះអាចទទួលយកបាន។

២. ប្រកាសថាអង្គជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រពីចៅក្រម៤(បួន)រូប យ៉ាងតិចដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តីនៃសំណើនេះបានឡើយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះ បិទផ្លូវតវ៉ា។ អង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងគាំទ្រភាគច្រើន ដូច្នេះកិច្ចស៊ើបសួរ ដែលត្រូវបានសុំមោឃភាពនេះ ត្រូវតម្កល់ទុកជាបានការ។

**រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៦**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **នេយ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។ ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK សូមលើកឡើងនូវមតិយោបល់របស់ខ្លួន ទាក់ទិននឹងអង្គសេចក្តីនៃពាក្យសុំ។

## យោបល់របស់ចៅក្រមជាតិ

## ១.រំឭកនីតិវិធី

21. នៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៦ សហមេធាវី [redacted] បានដាក់សំណើសុំឱ្យអង្គបុរេជំនុំជម្រះទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានាទាក់ទងនឹងទួលបេង ដោយហេតុថាកិច្ចស៊ើបសួរដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទងនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានាពាក់ព័ន្ធនឹងទួលបេង មានវិការៈ។[28] (សំណើសុំ)

22. នៅថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចលើពាក្យសុំរបស់ [redacted] ស្នើសុំទៅអង្គបុរេជំនុំជម្រះ សុំទទួលពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានា ទាក់ទងនឹងទួលបេង និងបទចោទនានាទាក់ទងនឹងទួលបេង ដោយបានសម្រេចអនុញ្ញាតតាមពាក្យសុំ ត្រង់ចំណុចទាក់ទងនឹងមោឃភាពកិច្ចស៊ើបសួរដែលបានធ្វើនៅមុនពេលមានដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤។[29] (ដីកាសម្រេចលើពាក្យសុំ [redacted])

23. នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ សហមេធាវី [redacted] បានដាក់សំណើបន្ថែម សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរលើទួលបេង និងវត្តអង្គញជី និងបទចោទប្រកាន់ទាក់ទងទៅនឹងទួលបេង ដោយសុំបន្ថែមទៅអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើបទចោទទាក់ទងនឹងវត្តអង្គញជីភ្ជាប់ជាមួយនឹងសំណើសុំធ្វើមោឃភាពកិច្ចស៊ើបសួរលើទួលបេង និងវត្តអង្គញជី។[30]

---

[28] សំណើសុំអង្គបុរេជំនុំជម្រះទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានាទាក់ទងនឹងទួលបេង ឯកសារលេខD299។

[29] ដីកាសម្រេចលើពាក្យសុំរបស់ [redacted] ស្នើប្តឹងទៅអង្គបុរេជំនុំជម្រះ សុំទទួលពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានាទាក់ទងនឹងទួលបេង ឯកសារD299/1។

[30] សំណើបន្ថែមលើសំណើរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរលើទួលបេង និងវត្តអង្គញជី និងបទចោទប្រកាន់ទាក់ទងនឹងទួលបេង ឯកសារD299/2។

24. នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំរបស់ [redacted] សុំមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី និងបទចោទនានាទាក់ទងនឹងទួលបេង។ (ចម្លើយតប)[31]

25. នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចរួមលើសំណើបន្ថែមរបស់ [redacted] សុំឱ្យអង្គបុរេជំនុំជម្រះទទួលពិចារណាអំពីមោឃភាពនៃកិច្ចស៊ើបសួរអំពីវត្តតាមាក់ និងទួលបេង និងវត្តអង្គញជី និងបទចោទនានាពាក់ព័ន្ធនឹងទួលបេង។[32]

26. អង្គបុរេជំនុំជម្រះប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍ ដោយពិនិត្យត្រឹមតែកិច្ចស៊ើបសួរដែលធ្វើឡើងនៅមុនពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមប៉ុណ្ណោះ ស្របតាមដីកាសម្រេចលើពាក្យសុំរបស់ [redacted][33]។

## ២. ឧទ្ធរណ៍របស់ភាគី

27. សហមេធាវីការពារក្តីបានលើកឡើងថាកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញជី មានវិការៈនីតិវិធី ដោយទីតាំងទាំងពីរនេះស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរដែលផ្តួចផ្តើមដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ និងពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលមានសុពលភាព ដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតទីតាំងឧក្រិដ្ឋកម្មថ្មីៗទាំងនោះ ដែលមានចែងក្នុងវិធាន៥៥(៣) នៃវិធានផ្ទៃក្នុងនោះទេ។[34]

28. សហមេធាវីការពារក្តីបន្តទៀតថាតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ សហចៅក្រមស៊ើបអន្តរជាតិបានធ្វើការស៊ើបអង្កេតទៅលើទីតាំងវត្តអង្គញជី និងទីតាំងទួលបេង មុនពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងអាពាហ៍

---

[31] ចម្លើយតប ឯកសារD299/3/1។

[32] ដីកាសម្រេចរួមលើសំណើបន្ថែមរបស់ [redacted] សុំឱ្យអង្គជំនុំជម្រះទទួលពិចារណាអំពីមោឃភាពនៃកិច្ចស៊ើបសួរអំពីវត្តតាមាក់ និងទួលបេង និងវត្តអង្គញជី និងបទចោទនានាពាក់ព័ន្ធនឹងទួលបេង ឯកសារD299/4។

[33] ដីកាសម្រេចលើពាក្យសុំរបស់ [redacted] កថាខណ្ឌ៣៧។

[34] សំណើសុំ កថាខណ្ឌ៤០។

ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤។[35] ចន្លោះពេលនោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិច១៥នាក់ ទាក់ទងនឹងទួលបេង និងវត្តអង្គញជី។[36] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ កំណត់អត្តសញ្ញាណ និងស្នើដល់សហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតទីតាំងឧក្រិដ្ឋកម្មជាក់លាក់ចំនួន១១កន្លែង ដូចបានរៀបរាប់ក្នុងកថាខណ្ឌ២៣ ដល់៣៦ និងកថាខណ្ឌ៤៩ ដល់៥៣ វត្តអង្គញជី និងវត្តទួលបេង មិនត្រូវដាក់បញ្ចូលក្នុងកថាខណ្ឌទាំងនេះទេ។ ការពិតដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣នេះ ដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ទាំងពីរនៅក្នុងស្រុកតែមួយនោះ គឺដោយសារថាទីតាំងនោះស្ថិតនៅចម្ងាយឆ្ងាយពេក ហើយពុំមានលក្ខណៈសម្បត្តិជាករណីលើកលែង អនុលោមតាមមាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[37]

29. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា [redacted] បានបកស្រាយខុសលើវិសាលភាពនៃកិច្ចស៊ើបសួរ ព្រោះគាត់មិនបានយកចិត្តទុកដាក់នឹង៥កថាខណ្ឌដំបូងនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគកណ្តាល ហើយបន្ទាប់មកបន្តទៀត ដោយរៀបរាប់ពីលក្ខខណ្ឌអាក្រក់ និងការកើនឡើងយ៉ាងគំហុក នៃការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន បន្ទាប់ពី[redacted] បានឡើងកាន់កាប់។ ហើយអង្គហេតុដែលបានរៀបរាប់នៅក្នុងកថាខណ្ឌទាំង៥ ទាក់ទងច្បាស់លាស់ទៅនឹងទឹកដីទាំងមូលនៃភូមិភាគកណ្តាល។[38]

30. សហព្រះរាជអាជ្ញាអន្តរជាតិបន្តទៀតថាកថាខណ្ឌ២២ ធ្វើកិច្ចការ២យ៉ាងច្បាស់លាស់។ មួយគឺប្តឹងទៅសហចៅក្រមស៊ើបអង្កេត អំពីការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន នៅទូទាំងទឹកដីទាំងស្រុងនៃភូមិភាគកណ្តាល និងទីពីរ កថាខណ្ឌនេះបានបង្ហាញឈ្មោះទីតាំងឧក្រិដ្ឋកម្ម [មួយ

[35] ដូចខាងលើ កថាខណ្ឌ៤១។

[36] ដូចខាងលើ កថាខណ្ឌ៤២។

[37] ដូចខាងលើ កថាខណ្ឌ៤៣។

[38] ចម្លើយតប កថាខណ្ឌ១៩ ដល់២០។

ចំនួន] ដែល[ជនរងគ្រោះទាំងអស់នេះ] ត្រូវបានឃុំខ្លួន និងសម្លាប់ចោលក្នុងអំឡុងពេលដែល [redacted] និងកម្មាភិបាលភូមិភាគនិរតី ចាប់ផ្តើមគ្រប់គ្រងនៅភូមិភាគកណ្តាល។[39]

31. សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថាពាក្យសុំរបស់ [redacted] បានផ្តោតតែទៅលើកថាខណ្ឌពី ២៣ ដល់៣៦ និងពី ៤៩ ដល់៥៣ ហើយសន្និដ្ឋានថា ពីព្រោះវត្តអង្គញដី និងទួលបេង មិនមានដាក់បញ្ចូលនូវកថាខណ្ឌទាំងនោះ ដែលដូច្នេះ ពួកវាស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ។[40]

32. សហព្រះរាជអាជ្ញអន្តរជាតិបន្ថែមទៀតថា [redacted] ខកខានមិនបានបង្ហាញឲ្យឃើញអំពីគ្រោះថ្នាក់ណាមួយឡើយដែលកើតចេញអំពីកំហុសដែលគាត់បានចោទប្រកាន់។ ហើយវិធាន៤៨ នៃវិធានផ្ទៃក្នុងចែងថា កិច្ចស៊ើបសួរ ឬកិច្ច អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។[41]

33. សហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ផងដែរថាការធ្វើមោឃភាពមិនមែនជាមធ្យោបាយសមរម្យទេ ប្រសិនបើអង្គបុរេជំនុំជម្រះ ទុកជាមោឃៈនូវកិច្ចស៊ើបសួរណាមួយទាក់ទងនឹងទីតាំងប្រធានបទនោះគ្មានអ្វីនឹងអាចរារាំង សហចៅក្រមស៊ើបអង្កេត ពីការមិនទទួលបានភស្តុតាងដូចគ្នាបេះបិទជាថ្មីម្តងទៀតនោះទេ។ អានុភាពតែមួយគត់នៃមោឃភាព គឺវានឹងធ្វើឲ្យមានការចំណាយពេល និងធនធានរបស់ អ.វ.ត.ក ដោយឥតប្រយោជន៍ និងធ្វើឲ្យមានការពន្យាពេលក្នុងការទទួលបានទាន់ពេលវេលានូវដំណោះស្រាយអំពីកិច្ចស៊ើបសួរ ដល់គ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង០០៤។[42]

## ៣.អង្គច្បាប់

34. វិធាន ៧៦ (២) នៃវិធានផ្ទៃក្នុងកំណត់ថា "ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ នៅពេលដែលភាគីទាំងឡាយយល់ឃើញថា មានផ្នែកណាមួយត្រូវបានចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំ

[39] ដូចខាងលើ កថាខណ្ឌ២២ ដល់២៣។

[40] ដូចខាងលើ កថាខណ្ឌ២៤។

[41] ដូចខាងលើ កថាខណ្ឌ២៧។

[42] ដូចខាងលើ កថាខណ្ឌ៣២។

ដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេត ដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្ដឹងទៅអង្គបុរេជំនុំជម្រះស្នើសុំឱ្យធ្វើមោឃភាព។ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដែលអាចជាការទទួលយក ឬបដិសេធសំណើសុំភ្លាមៗតាមតែអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់ត្រូវធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ។ វិធានវិធាន ៤៨ នៃវិធានផ្ទៃក្នុង ចែងថា "កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិ ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។

35. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា អ.វ.ត.ក ត្រូវបានបង្កើតឡើងតាម កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង), ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់ អ.វ.ត.ក) និងអនុវត្តវិធានផ្ទៃក្នុង។

36. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរ ខុសពីតុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា។ ការចោទប្រកាន់ និងការស៊ើបសួររបស់តុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា គឺធ្វើឡើងតែលើអង្គហេតុទេ មានន័យថាមិនមែនជាការចោទប្រកាន់ និងការស៊ើបសួរលើបុគ្គលឡើយ [43] ។ ផ្ទុយមកវិញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ និងការស៊ើបសួរ អាចធ្វើទៅបាន លុះត្រាបំពេញលក្ខខណ្ឌពីរ គឺ ទី១ អង្គហេតុ."ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩" និង ទី២ លបុគ្គ."មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[44]។

[43] មាត្រា ៤៤ និង ១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[44] មាត្រា ១ នៃច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។

37. ហេតុដូច្នេះចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណា ថាតើកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបានធ្វើនៅមុនពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បំពាននូវលក្ខខណ្ឌដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ៣៦ ដែលនាំឱ្យមិនគោរពវិធានបញ្ញត្តិនៃការស៊ើបសួរដូចដែលបានពន្យល់នៅក្នុងកថាខណ្ឌ ៣៤ ខាងលើ ជាហេតុធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ [redacted] និងនាំឱ្យមោឃៈ ដែរ ឬទេ។

38. សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានខ្វែងយោបល់គ្នាចំពោះការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៤ នេះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣។ រីឯសហព្រះរាជអាជ្ញាជាតិបានបដិសេធចោលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ ផ្អែកលើមូលដ្ឋាន “ជនសង្ស័យទាំងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត”[45] ហើយចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក៏បានខ្វែងយោបល់គ្នាចំពោះបញ្ហានេះដែរ ដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ គាំទ្រទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ[46]។

39. តាមការយល់ឃើញខាងលើចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា កិច្ចស៊ើបសួរដែលបានធ្វើទៅលើទីតាំងទួលបេង និងវត្តអង្គញជី ត្រូវចាត់ទុកជាមោឃៈ។

**ភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦**

**ចៅក្រម ប្រាក់ គឹមសាន** **ចៅក្រម ន័យ ផុល** **ចៅក្រម ហួត វុទ្ធី**

---

[45] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឱ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៩ កថាខណ្ឌទី ៨៦ (ក)។

[46] យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៩ “[redacted] មិនមែនជា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម”។

01363226



# យោបល់របស់ចៅក្រមអន្តរជាតិទៅលើសំណើសុំ

## ក. សារណារបស់ភាគី

### ១. សំណើសុំរបស់ [redacted]

40. [redacted] បានស្នើសុំដល់អង្គបុរេជំនុំជម្រះ ធ្វើមោឃភាពបទចោទ និងកិច្ចស៊ើបសួរដែលរងការជំទាស់ ទាក់ទងទួលបេង[47]។ សំណើសុំរបស់ [redacted] ផ្អែកលើមូលដ្ឋានដែលថា បទចោទនិងកិច្ចស៊ើបសួរបែបនេះ មានកំហុសនីតិវិធី ហើយកំហុសនីតិវិធីទាំងអស់នេះ បានរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ [redacted] ក្នុងការដឹងអំពីសំណុំរឿងប្រឆាំងរូបគាត់ និងសិទ្ធិក្នុងការរៀបចំការការពារក្តីរបស់គាត់[48]។

41. [redacted] បានលើកឡើងថា កិច្ចស៊ើបសួរដែលរងការជំទាស់ ដែលធ្វើឡើងមុនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ ត្រូវបានអនុវត្តដោយមិនមានការផ្តល់សិទ្ធិ ពីសហព្រះរាជអាជ្ញា ដូច្នេះហើយកិច្ចស៊ើបសួរនេះមានកំហុសនីតិវិធី ព្រោះ ១) ទួលបេង ឬវត្តអង្គញដី មិនបានបញ្ចូលទៅក្នុង ទីតាំងឧក្រិដ្ឋកម្មជាក់លាក់ទាំង១១ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ[49] និង ២) ការដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងពីរ ដូចជា គោកព្រីង និងភ្នំប្រុស ដែលស្ថិតក្នុងស្រុកកំពង់សៀមតែមួយ ជាមួយទួលបេង និងវត្តអង្គញដីនោះ គឺមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចំពោះអ្វីដែលអាចកើតឡើងនៅទីតាំងទួលបេង និងវត្តអង្គញដី ជា "ស្ថានទម្ងន់" នៃអង្គហេតុដែលស្ថិតក្រោម ការស៊ើបសួរតាមផ្លូវតុលាការឡើយ[50]។ [redacted] បានជំទាស់ថា ហេតុដូច្នេះការចោទប្រកាន់ថា ទួល បេង និងវត្តអង្គញដី គឺជាមន្ទីរសន្តិសុខ ឬ

[47] សំណើសុំ, កថាខណ្ឌ ៦៦។

[48] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២, ៦៦។

[49] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៤៣។

[50] *ដូចជើងទំព័រខាងលើ កថាខណ្ឌ* ៤៣ និងជើងទំព័រ ៤៦៖ "អត្ថិភាពដែលរងការចោទប្រកាន់នៃ ទួលបេង និងវត្តអង្គញដី ក្នុងស្រុកកំពង់សៀម មិនមែនជា "ស្ថានទម្ងន់" នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ នៅគោកព្រីង និងភ្នំប្រុសទេ")។

ទីតាំងសម្លាប់មនុស្ស គឺជាអង្គហេតុថ្មីដែលតម្រូវឲ្យមាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[51]។

42. [redacted]បានលើកឡើងបន្ថែមថា ដោយសារមិនមាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម លម្អិតគ្រប់គ្រាន់នោះ ការពង្រីកកិច្ចស៊ើបសួរដោយរួមបញ្ចូល ទួល បេង និងវត្តអង្គញជី បាន រំលោភបំពានទៅលើសិទ្ធិរបស់ [redacted] ដែលត្រូវបានធានាដោយមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលត្រូវជូនដំណឹងភ្លាមៗ និងដោយលម្អិត អំពីរឿងក្ដីប្រឆាំងរូបគាត់ ហើយជាលទ្ធផលគឺសិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់ត្រៀមរៀបចំរឿងក្ដីរបស់គាត់[52]។ [redacted] កត់សម្គាល់ថា កំហុសនីតិវិធីដែលបានរៀបរាប់ខាងលើ និងមធ្យោបាយ "មិនអចិន្ត្រៃយ៍" របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការពង្រីកកិច្ចស៊ើបសួរ មិនមានភាពស៊ីសង្វាក់គ្នាផ្នែកអង្គសេចក្ដី ហើយបានបង្កើតនូវភាពមិនច្បាស់លាស់ ថាតើទីតាំងឧក្រិដ្ឋកម្មណាមួយ ដែលពួកគេកំពុងធ្វើការស៊ើបសួរ និងការចោទប្រកាន់ពីតួនាទី ដែលទីតាំងឧក្រិដ្ឋកម្មនេះមាន ក្នុងការចោទប្រកាន់ដែលធ្វើឡើងប្រឆាំងរូបគាត់[53]។

## ២. ចម្លើយតបរបស់សហព្រះរាជអាជ្ញា

43. សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើដល់អង្គបុរេជំនុំជម្រះ ឲ្យច្រានចោលសំណើរបស់ [redacted] សុំមោឃភាពកិច្ចស៊ើបសួរដែលរងការជំទាស់[54]។

44. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា មិនមានកំហុសនីតិវិធីឡើយ ព្រោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅ វត្តអង្គញជី និងទួលបេង ពិតជាស្ថិតក្នុងវិសាលភាព នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[55]។ សហព្រះរាជអាជ្ញាអន្តរជាតិបានកត់សម្គាល់ថា [redacted]បកស្រាយខុសនូវវិសាលភាពនៃកិច្ចស៊ើបសួរ ដោយមិនយកចិត្តទុកដាក់លើកថាខណ្ឌ ១៨ ដល់២២ នៃដីកាសន្និដ្ឋាន

---

[51] សំណើសុំ, កថាខណ្ឌ ៤៤។

[52] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦០ ដល់៦៥។

[53] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៦៤។

[54] ចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៤។

[55] ចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា, កថាខណ្ឌ ១៩ ដល់២៤។

01363228



បញ្ជូនរឿងឱ្យស៊ើបសួរ ទាក់ទងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត នៅភូមិភាគកណ្តាល ដែលរៀបរាប់ពីស្ថានភាពកាន់តែអាក្រក់ ព្រមទាំងការកើនឡើងយ៉ាងគំហុកនូវការចាប់ខ្លួន ការសម្លាប់ និងការបាត់ខ្លួន បន្ទាប់ពី [redacted] ឡើងកាន់កាប់[56]។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ពាក្យពេចន៍យ៉ាងច្បាស់លាស់នៃកថាខណ្ឌ ២២ បានបញ្ជាក់ច្បាស់ថា (១) សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹង ពីការចាប់ខ្លួន ការសម្លាប់ ការបាត់ខ្លួន នៅទូទាំងភូមិភាគកណ្តាល[57] និង (២) បញ្ជីឈ្មោះទីតាំងឧក្រិដ្ឋកម្មជាក់លាក់ គឺមិនច្រើនទេ ព្រោះបានបញ្ជាក់យ៉ាងច្បាស់ថា ទីកន្លែងដែលបានរៀបរាប់គឺ "ជាទីតាំងឧក្រិដ្ឋកម្ម[មួយចំនួន] ដែល [ជនរងគ្រោះទាំងអស់នេះ] ត្រូវបានឃុំខ្លួន និងសម្លាប់ក្នុងអំឡុងពេលដែល[redacted] និងកម្មាភិបាលភូមិភាគនិរតី ចាប់ផ្តើមគ្រប់គ្រងនៅភូមិភាគកណ្តាល"[58]។

45. សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់ថា មិនមានការរំលោភបំពានទៅលើ សិទ្ធិជាសារវន្តរបស់ [redacted] ឡើយ ដូច្នេះហើយការធ្វើមោឃភាពគឺមិនមានអង្គសេចក្តីឡើយ ដោយសារ [redacted] មិនបានបំពេញតួនាទី ក្នុងការបង្ហាញពីព្យសនកម្ម ដែលបណ្តាលមកពីកំហុសឆ្គងដែលបានចោទប្រកាន់ បើទោះបីជាកំហុសនីតិវិធីត្រូវបានកំណត់ក៏ដោយ[59]។

46. ជាចុងក្រោយសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថាបើទោះបីជាអាចកំណត់បានពីអត្ថិភាពនៃកំហុសនីតិវិធី និងព្យសនកម្មក៏ដោយ បើតាមកាលៈទេសៈនៃសំណុំរឿងនេះ ការធ្វើមោឃភាពគឺជាឧបាស្រ័យដែលមិនត្រឹមត្រូវ និងជ្រុលហួសហេតុ[60]។

## ខ. ពិភាក្សា

47. អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថាវិសាលភាពនៃកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតត្រូវបានកំណត់ដោយវិធាន៥៣(១) និង(២), និង៥៥(១),(២) និង(៣)[61] នៃវិធានផ្ទៃក្នុង។ វិធាន

---

[56] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១៩។

[57] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២២។

[58] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៣។

[59] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៧ ដល់២៩។

[60] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣០ ដល់៣៣។

៥៥(២)នៃវិធានផ្ទៃក្នុងចែងថា [62] "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណាដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតពុំត្រូវបានអនុញ្ញាតឱ្យស៊ើបសួរអំពីអង្គហេតុនានាដែលស្ថិតនៅក្រៅវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ[63]។

48. វិធាន៥៥(៣) ចែងថា [64] "ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះជា*ស្ថានទម្ងន់ទោស*នៃអង្គហេតុដែលមានកំណត់ក្នុងដីកាសន្និដ្ឋានដែលមានស្រាប់"។ កាលណាអង្គហេតុថ្មីនេះត្រូវបានបញ្ជូនទៅឱ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា"។ "អង្គហេតុថ្មី" "គឺជាព្រឹត្តិការណ៍ទាំងឡាយណាដែលបានកើតឡើង ឬក៏ត្រូវបានលាតត្រដាង ក្រោយពេលបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរហើយ"[65]។ រាល់អង្គហេតុណាដែលពុំមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនស្ថិតនៅក្នុងដែន

---

[61] សាលដីកាខ្លួន ជា, កថាខណ្ឌ ១៦។ សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយដែលចោទប្រកាន់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" , ឯកសារ D99/3/42, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨ ("សាលដីកា ឌុច"), កថាខណ្ឌ ៣៤។ *សូមមើលផងដែរ* វិធាន ៥៣(១) និង(២) នៃវិធានផ្ទៃក្នុងដែលចែងត្រង់ផ្នែកពាក់ព័ន្ធ៖ "(១) សហព្រះរាជអាជ្ញា [...] ត្រូវបើកការស៊ើបសួរដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត [...], (២) ដីកា*ត្រូវអមដោយសំណុំរឿង និងសម្ភារៈដទៃទៀតដែលបានចាត់ទុកជាភស្តុតាងដែលសហព្រះរាជអាជ្ញាមាន* [...]"។ វិធាន៥៥(១)នៃវិធានផ្ទៃក្នុង ("ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ")។

[62] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា ១២៤(៣) ("ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ")។

[63] សាលដីកាលើពាក្យសុំចំនួន២របស់ [redacted], កថាខណ្ឌ ៩។

[64] *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា១២៥។ ក្រមព្រហ្មទណ្ឌបារាំង, មាត្រា ៨០ ("[បកប្រែ] ចៅក្រមស៊ើបសួរអាចស៊ើបអង្កេតតែតាមរយៈដីកាសន្និដ្ឋានដែលធ្វើឡើងដោយរដ្ឋអាជ្ញាសាធារណៈប៉ុណ្ណោះ")។

[65] សាលដីកាលើពាក្យសុំចំនួន២របស់ [redacted] (យោបល់របស់ចៅក្រម Beauvallet និង Bwana), កថាខណ្ឌ ១១។

សមត្ថកិច្ចរបស់ចៅក្រមស៊ើបអង្កេតទេ វៀរលែងតែមានការពង្រីកវិសាលភាពនៃការស៊ើបអង្កេតនាពេលក្រោយមកទៀត តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម [66]។

49. អង្គបុរេជំនុំជម្រះបានកត់សម្គាល់ពីពេលមុនថា “សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធ្វើការស៊ើបសួរលើ*អង្គហេតុទាំងអស់* ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម” [67] និងសំខាន់ជាងនេះទៀត “សហចៅក្រមស៊ើបអង្កេតក៏ទទួលបានកាលៈទេសៈជុំវិញអំពើទាំងឡាយ ដែលរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម”[68]។ អង្គបុរេជំនុំជម្រះបានកំណត់ថាកាលៈទេសៈជុំវិញនេះជា “កាលៈទេសៈដែល*គេចោទថាឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង ហើយនាំដល់ការកំណត់បទចោទមិនត្រូវបានគេយល់ឃើញថាជាអង្គហេតុថ្មី*” [69] ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ទៀតថាកាលៈទេសៈទាំងនោះ “មិនត្រូវបានគេយល់ឃើញថាជាអង្គហេតុថ្មីឡើយ ហេតុដូច្នេះហើយកាលៈទេសៈទាំងនេះជាផ្នែកមួយនៃការស៊ើបសួរ”[70]។

50. ជាពិសេសទាក់ទងនឹងទីតាំងនានាដែលពុំមានលើកឡើងច្បាស់លាស់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ “ដោយសង្ខេប ទីតាំងប្រព្រឹត្តជាកម្មទេសកាលកន្លែងរបស់អង្គហេតុ គឺមិនមែនអង្គហេតុផ្ទាល់នោះទេ” [71] ។ បើទោះបីជា “សហចៅក្រមស៊ើបអង្កេតត្រូវកំណត់ព្រំដែននៃការស៊ើបអង្កេតមកត្រឹមអង្គហេតុឧក្រិដ្ឋជាសក្តានុពលដែលកំណត់ដោយសហព្រះរាជអាជ្ញា” ក៏ដោយ “ចៅក្រមទទួលបន្ទុកក្នុងការបង្ហាញកាលៈទេសៈនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម ជាពិសេសគឺបង្ហាញទីតាំងដែលអំពើឧក្រិដ្ឋនោះបានកើតឡើង”[72]។ លើសពីនេះ ទោះបីជាមិនដឹងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់ក៏ដោយ ក៏សហព្រះរាជអាជ្ញាអន្តរជាតិមានហេតុផលជឿជាក់ថាឧក្រិដ្ឋកម្មដែលខ្លួនបញ្ជូនទៅ

---

66 *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ៩។

67 សាលដីកា ឌុច, កថាខណ្ឌ ៣៥។

68 *ដូចឯកសារយោងខាងលើ*។

69 *ដូចឯកសារយោងខាងលើ*។

70 *ដូចឯកសារយោងខាងលើ*។

71 សាលដីកាលើពាក្យសុំចំនួន២របស់ [redacted], (យោបល់របស់ចៅក្រម Beauvallet និង Bwana), កថាខណ្ឌ ១៩។

72 *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ១៤។

សហចៅក្រមស៊ើបអង្កេតឱ្យស៊ើបសួរ ត្រូវបានប្រព្រឹត្តមិនត្រឹមតែនៅទីតាំងដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះទេ គឺឧក្រិដ្ឋកម្មទាំងនេះថែមទាំងត្រូវបានប្រព្រឹត្តនៅទីតាំងផ្សេងទៀតដែលសហចៅក្រមស៊ើបអង្កេតត្រូវស្វែងរកឱ្យឃើញ[73]។

51. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះរក្សាទស្សនៈដែលថានៅពេលទីតាំងនានា ដែលមិនមានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រួមចំណែកដល់ការកំណត់បទចោទនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ តាមរយៈការបង្ហាញអត្តសញ្ញាណ និងបន្ថែមព័ត៌មានអំពីអង្គហេតុនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ អង្គហេតុដែលទាក់ទងនឹងទីតាំងទាំងនោះពុំមែនជាអង្គហេតុថ្មីដែលតម្រូវឱ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ។ ប៉ុន្តែ អង្គហេតុទាំងនោះជាកាលៈទេសៈជុំវិញដែលទាក់ទងនឹងអង្គហេតុនានាដែលស្ថិតនៅទាំងស្រុងក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ។

52. ជាងនេះទៀត "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ *និងឧបសម្ព័ន្ធរបស់វា*" ត្រូវបានពិនិត្យដូចៗគ្នាទាំងពីរ នៅពេលវិភាគថាតើកិច្ចស៊ើបសួរនៃកិច្ចស៊ើបសួរស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរឬទេ[74]។ កាលណា "ទីតាំងទាំងនោះមិនមានរៀបរាប់ឱ្យបានជាក់ច្បាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏អង្គហេតុដែលត្រូវបានប្រព្រឹត្តនៅទីតាំងទាំងនេះអាចបញ្ចូលក្នុងដីកាសុំឱ្យស៊ើបអ្វីស៊ើបហ្នឹងបានដែរ ប្រសិនបើអង្គហេតុទាំងនេះមានរៀបរាប់ដោយប្រយោលនៅក្នុងដីកា

[73] សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៣") (អ.ប.ជ ២៨), សាលដីការបស់អង្គជំនុំជម្រះ ១) លើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួនប្រាំបួនរបស់ [redacted] សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួន២ដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦, ឯកសារ D165/2/26 ("សាលដីកាលើសំណើចំនួន៩ របស់ [redacted]"), (យោបល់របស់ចៅក្រម Beauvallet និង Baik), កថាខណ្ឌ ១៩៨។

[74] សាលដីកាលើសំណើចំនួន ២ របស់ [redacted], (យោបល់របស់ចៅក្រម Beauvallet និង Bwana), កថាខណ្ឌ ៤។ សាលដីកាលើសំណើចំនួន៩ របស់ [redacted], (យោបល់របស់ចៅក្រម Beauvallet និង Baik), កថាខណ្ឌ ១៥០។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ"[75]។ ហេតុដូច្នេះ អង្គហេតុនានាដែលមានក្នុងភស្តុតាងភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្ថិតនៅទាំងស្រុងក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ[76]។

53. ចៅក្រមដែលចុះហត្ថលេខាត្រូវពិនិត្យថាតើ ទួលបេង និងវត្តអង្គញជី ស្ថិតក្នុងការចោទប្រកាន់ដែលមានក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងឯកសារភ្ជាប់របស់វាដែរឬទេ ដើម្បីសម្រេចថាតើកិច្ចស៊ើបសួរដែលរងការជំទាស់ស្ថិតក្រោមវិសាលភាពនៃកិច្ចស៊ើបសួរឬទេ[77]។

54. ចៅក្រមដែលចុះហត្ថលេខាសង្កេតឃើញថា ស.ព.អ បានស្នើសុំឱ្យ ស.ច.ស.អ បើកកិច្ចស៊ើបសួរអំពីអង្គ ហេតុនានា "ដូចបានកំណត់នៅក្នុងកថាខណ្ឌ ១៨-៥៣" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាក់ទងនឹង ក្នុងចំណោមបទចោទផ្សេងៗ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានដូចជា៖ "ការធ្វើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើឱ្យទៅជាទាសករ, ការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការរំលោភលើផ្លូវភេទ, ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា ទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ វណ្ណៈសក្តិភូមិ នាយទុន និងគហបតី, "ប្រជាជនថ្មី", អ្នកជាប់សង្ស័យជា "សមាសភាពអាក្រក់", ជនជាតិចាម និងជនជាតិភាគតិចវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត"[78]។ បទល្មើសទាំងនេះត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅភូមិភាគកណ្តាល, ខេត្តកំពង់ចាម និងត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តក្រោមការគ្រប់គ្រង របស់ [redacted] គណៈតំបន់ ៤១ ដែល "រៀបចំផែនការ, បានញុះញង់, បានបញ្ជា, និងជួយនិងជំរុញ ឬបានប្រព្រឹត្ត" បទល្មើសទាំងនោះ[79]។ [redacted] គណៈស្រុកកំពង់សៀមក្នុងខេត្ត

---

[75] សាលដីកាលើសំណើចំនួន២របស់ [redacted], (យោបល់របស់ចៅក្រម Beauvallet និង Bwana), កថាខណ្ឌ ១៩។

[76] *សូមមើលផងដែរ* វិធាន៥៣(២) ដីកានេះ *ត្រូវអមដោយសំណុំរឿង និងសម្ភារៈដទៃទៀតដែលបានចាត់ទុកជាភស្តុតាងដែលសហព្រះរាជអាជ្ញាមាន* [...]"។

[77] *ដូចឯកសារយោងខាងលើ*។

[78] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ១១៧។

[79] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ១០៩ និង ១៨-៥៣។

កំពង់ចាម ត្រូវបានចោទប្រកាន់ថាស្ថិតក្នុងចំណោមអ្នកទាំងឡាយដែល "បានរាយការណ៍ទៅ" និង "មានទំនាក់ទំនងជិតស្និទ្ធជាមួយ" [redacted][80]។

55. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកឡើងអំពីបញ្ជីមិនលម្អិតនៃទីតាំងឧក្រិដ្ឋកម្មដែលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ បានកើតឡើងតាមរយៈការផ្តល់ "ទីតាំងឧក្រិដ្ឋកម្ម*ខ្លះៗ*ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មទាំងនោះ" ដែលរួមបញ្ចូលមន្ទីរសន្តិសុខភ្នំប្រុស និងទីកន្លែងសម្លាប់គោកព្រីង ក្នុងស្រុកកំពង់សៀម[81]។ បើទោះបីជាមេដឹកនាំជាន់ខ្ពស់នៃភូមិភាគកណ្តាលត្រូវបាននាំខ្លួនទៅមន្ទីរ ស-២១ ក៏ដោយ[82] ក៏មនុស្សចំនួនជាង ១ ម៉ឺននាក់ដែល "ជាប់ខ្សែរយៈសង្គមចាស់" និងមនុស្សដែលជាប់ទាក់ទងនឹងកម្មាភិបាលដែលជាប់សង្ស័យ ត្រូវបានសម្លាប់នៅភ្នំប្រុសដែល "ប្រហែលជាគុកថ្នាក់ភូមិភាគ ប្រសិនបើមិនមែនគ្រាន់តែជាគុកថ្នាក់តំបន់"[83] ហើយ "ប្រជាជន១៧មេសា" ចំនួនប្រហែល ១ ពាន់នាក់ត្រូវបានសម្លាប់នៅគោកព្រីង[84]។

56. ចៅក្រមដែលចុះហត្ថលេខាកត់សម្គាល់ឃើញថាទោះបីជាទួលបេង និងវត្តអង្គុញដី ពុំមានបញ្ជាក់ច្បាស់ថាជា ទីតាំងឧក្រិដ្ឋកម្មមួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មគំរូក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏ទីតាំងទាំងពីរត្រូវបានលើកឡើងក្នុងឯកសារភ្ជាប់នៃដីកានោះ ថាជាទីតាំងសក្តានុពលដែល ទាក់ទងនឹងទីតាំងនានាដែលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ អាចត្រូវបានប្រព្រឹត្តក្នុងស្រុកកំពង់សៀម[85]។ ជាពិសេស ឯកសារភ្ជាប់ D1.3.11.13 បង្ហាញថាអាចមានមន្ទីរសន្តិសុខ

---

[80] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ៣០-៣៣ (សេចក្តីបញ្ជាក់បន្ថែម)។

[81] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ២២ និងកថាខណ្ឌ ៣០-៣៣។

[82] *ដូចឯកសារយោងខាងលើ,* កថាខណ្ឌ ២០។

[83] របាយការណ៍ស្តីពីទស្សនកិច្ចរបស់ក្រុមគូសផែនទី CGP ទៅកាន់ខេត្តកំពង់ចាម, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1.3.10.5, ត្រង់ ERN 00208309, ERN 00208307-00208313 (ភាសាអង់គ្លេស) ទំព័រទី៣។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣០-៣១។

[84] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣២-៣៣។

[85] *សូមមើល* កិច្ចសម្ភាសន៍ [redacted] (កិច្ចសម្ភាសន៍ ក.ស.ព-00022), ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1.3.11.13, ត្រង់ ERN 00210445-00210449 (ភាសាអង់គ្លេស) ទំព័រ៣,៥ ឬ ERN 00210447 និង 00210449 ដែលត្រូវបានដកស្រង់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រង់ជើងទំព័រ ៣៨, ៤២, ៩១, ៩៤, ៩៨, ៩៩, ៣៦៣ ("កិច្ចសម្ភាសន៍ [redacted]"), របាយការណ៍បេសកកម្មរបស់ ក.ស.ព ទៅកាន់តំបន់ ៤១ (ប្រតិបត្តិការនៅលើទឹកដីតាមដងទន្លេ), ថ្ងៃទី ២០ ខែ

មួយនៅទួលបេង និងមន្ទីរស្រុកសម្រាប់ស្រុកកំពង់សៀមនៅវត្តអង្គញដី [86] ។ ពិសេសជាងនេះ សាក្សីទាំងនេះនិយាយថាភាគច្រើននៃមនុស្សទាំងអស់នោះ ដែលត្រូវបានគេយកទៅភូមិអង្គញដី ត្រូវបានបញ្ជូនទៅសម្លាប់នៅទីកន្លែងសម្លាប់មនុស្សគោកព្រីង[87]។

57. ហេតុដូច្នេះ ចៅក្រមដែលចុះហត្ថលេខាយល់ឃើញថាក្រោយពីវិភាគល្អិតល្អន់អំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ ស៊ើបសួរ និងឯកសារភ្ជាប់របស់វា ការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់នៅទីតាំងនីមួយៗក្នុងស្រុកកំពង់សៀម គឺមានទំនាក់ទំនងគ្នាលើផ្នែកប្រតិបត្តិការ[88]។ ពិសេសជាងនេះទៀត ទោះបីជា ភ្នំប្រុសជា "មន្ទីរសន្តិសុខ" មួយក្នុងស្រុកកំពង់សៀមនៃភូមិភាគកណ្តាលដែលប្រជាជន "ពាក់ព័ន្ធនឹងសង្គមចាស់" និងអ្នកដែលជាប់ខ្សែកម្មាភិបាលដែលជាប់សង្ស័យ ត្រូវបានឃុំឃាំង និងសម្លាប់ក៏ដោយ[89] ក៏ទីតាំងវត្តអង្គញដីបានបំពេញមុខងារជាមន្ទីរស្រុកកំពង់សៀមដែលអ្នកដែលត្រូវបានគេចាត់ទុកជាខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានសួរចម្លើយ និងឃុំឃាំងបណ្តោះអាសន្ន មុនពេលគេយកទៅមន្ទីរសន្តិសុខ ឬទីកន្លែងសម្លាប់នានាក្នុងស្រុកដែលដូចជា ភ្នំប្រុស[90] គោកព្រីង[91] និងទួលបេង[92]។

---

វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1.3.10.23, ERN 00211152-00211171(ភាសាអង់គ្លេស) ទំព័រទី១០ ឬ ERN 00211161 ដែលត្រូវបានដកស្រង់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ ស៊ើបសួរត្រង់ជើងទំព័រ ៨៣, ៨៥, ៩០។

[86] កិច្ចសម្ភាសន៍ [redacted], ទំព័រ ៥ ឬ ERN 00210449 "ខ្ញុំមិនដឹងថានៅអង្គញដីមានមន្ទីរសន្តិសុខឬអត់ទេ។ [មនុស្សម្នាក់ដែលបានឈរមើល ការសម្ភាសន៍ឈ្មោះ [redacted] បានឆ្លើយកាត់ថា *មានមន្ទីរសន្តិសុខមួយកន្លែងនៅទួលបេង (ដែលអាចមើលឃើញក្នុងផែនទី របស់យើងស្ថិតក្នុងភូមិមួយនៅជិតភូមិអង្គញដី*)]។ សូមមើលផងដែរកិច្ចសម្ភាសន៍ [redacted], ទំព័រ ១០៖ "ក្នុងសម័យខ្មែរក្រហម មន្ទីរស្រុកកំពង់សៀមស្ថិតនៅភូមិអង្គញដី ឃុំក្រឡា"។

[87] កិច្ចសម្ភាសន៍ [redacted], ទំព័រ ៥ ("ពាក្យ "នាំយកចេញ" មានន័យថាសម្លាប់។ [...] *មនុស្សភាគច្រើនដែលត្រូវនាំយកចេញទៅគឺត្រូវយកទៅសម្លាប់នៅគោកព្រីង*។ [ប្អូនប្រុសរបស់ខ្ញុំ] ប្រហែលជាត្រូវគេយកទៅភូមិអង្គញដី។ [...] មិនឃើញគាត់ត្រឡប់មកវិញទេ")។ *សូមមើលផងដែរ* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣២។

[88] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ២០-២២, ៣១-៣២។

[89] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ៣១។ របាយការណ៍ស្តីពីទស្សនកិច្ចរបស់ក្រុមគូសផែន CGP ទៅកាន់ខេត្តកំពង់ចាម, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1.3.10.5 ត្រង់ ERN 00208309, ERN 00208307-00208313 (ភាសាអង់គ្លេស)។

[90] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣០-៣១។

[91] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ៣២-៣៣។

[92] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ៣២, កិច្ចសម្ភាសន៍ [redacted], ទំព័រ ៥។

58. លើសពីនេះ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបង្ហាញច្បាស់ថា [redacted] គឺជាមនុស្សក្រោមបង្គាប់របស់ [redacted] និងបានអនុវត្ត និងបានរក្សាការត្រួតត្រាទៅលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅស្រុកកំពង់សៀម[93]។ [redacted] មានទំនាក់ទំនងជិតស្និទ្ធជាមួយ [redacted][94] ពីព្រោះ [redacted] ជាតំណាងកសិករភូមិភាគនិរតី ជាមួយ [redacted] ក្នុងសភាតំណាងប្រជាជនក្នុងខែមីនា ឆ្នាំ ១៩៧៦ និងបានធ្វើការជាមួយ [redacted] ក្នុងតំបន់ ៣៥ នៃភូមិភាគនិរតី មុនពេលគាត់បានធ្វើដំណើរជាមួយ [redacted] ទៅភូមិភាគកណ្ដាលនៅដើមឆ្នាំ ១៩៧៧[95]។ ជាងនេះទៀត [redacted] ក្នុងនាមជាគណៈស្រុកកំពង់សៀម បានធ្វើការនៅមន្ទីរស្រុកនេះក្នុងភូមិអង្គញជី[96]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានលើកឡើងយ៉ាងច្បាស់ថា *ឈ្លប* ដែលបានយកមនុស្សទៅគោកព្រីង ត្រូវបានជ្រើសរើសដោយ និងធ្វើការឱ្យ [redacted][97] និងថា [redacted] បានរាយការណ៍ទៅគណៈតំបន់ [redacted][98]។

59. ចៅក្រមដែលចុះហត្ថលេខា ក៏កត់សម្គាល់ផងដែរអំពីភាពជិតគ្នានៃភូមិសាស្ត្ររវាងទីតាំងទាំងនេះ និងការពិតដែលថាមន្ទីរស្រុកដែលស្ថិតក្នុងភូមិអង្គញជីនេះ មានទីតាំងយុទ្ធសាស្ត្រចន្លោះពីភ្នំប្រុសទៅទីតាំងគោកព្រីង [99] ។ ទីកន្លែងទាំង៤-ទួលបេង និងវត្តអង្គញជីក្នុងឃុំក្រឡា, ភ្នំប្រុសក្នុងឃុំ

---

[93] *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣១,៣៣។ ឧបសម្ព័ន្ធ ខ៖បញ្ជីឈ្មោះសាក្សី, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1.2, ទំព័រ ២៣-២៤។ កិច្ចសម្ភាសន៍ [redacted], ទំព័រ ២។

[94] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣១។

[95] *ដូចឯកសារយោងខាងលើ,* ឧបសម្ព័ន្ធ ខ៖ បញ្ជីឈ្មោះសាក្សី, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1.2, ទំព័រ ២៣-២៤។

[96] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣១។ កិច្ចសម្ភាសន៍ [redacted], ទំព័រ ៣ ("ការិយាល័យស្រុកកាលពីសម័យខ្មែរក្រហមមានទីតាំងនៅក្នុងភូមិអង្គញជី") និងទំព័រ ៥ ("ខ្ញុំមិនអាចចាំឈ្មោះនរណាម្នាក់ដែលធ្លាប់ធ្វើការងារនៅការិយាល័យស្រុកជាមួយ [redacted] បានទេ")។

[97] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ៣៣។

[98] *ដូចឯកសារយោងខាងលើ។ សូមមើលផងដែរ* កិច្ចសម្ភាសន៍ [redacted], ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D.1.3.11.11, ដែលត្រូវបានដកស្រង់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រង់ជើងទំព័រ ២៥,៣៩,៤១,៤៨,៩៣,៩៩,៣៥៤,៣៦៤,៣៧៣,៣៩២, ទំព័រ ២។

[99] *សូមមើល* របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស, ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៤។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ D117/48, ទំព័រ ២។ របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរ

អំពិល និងឃុំក្រឡា និងគោកព្រីងក្នុងឃុំវិហារធំ-ស្ថិតនៅចម្ងាយពីគ្នាតែប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះ ហើយឃុំអំពិល, ក្រឡា និងឃុំវិហារធំស្ថិតនៅជាប់គ្នាដោយផ្ទាល់[100]។ ដោយពិចារណាអំពីលក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងវិសាលភាពនៃសិទ្ធិអំណាចរបស់[redacted] ទៅលើស្រុកកំពង់សៀម យើងអាចសន្និដ្ឋានថាមន្ទីរស្រុកកំពង់សៀមដែលស្ថិតនៅវត្តអង្គញដី បានបំពេញមុខងារជាមន្ទីរបញ្ជាការសម្រាប់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងស្រុកកំពង់សៀម។ ហេតុដូច្នេះ ចៅក្រមដែលចុះហត្ថលេខាយល់ឃើញថាទំនាក់ទំនងប្រតិបត្តិការផ្ទាល់ និងមិនអាចបំបែកបាន បានមានអត្ថិភាពរវាងទីតាំងទួលបេង និងវត្តអង្គញដី និងទីតាំងភ្នំប្រុស និងទីតាំងគោកព្រីង។

60. ហេតុដូច្នេះ ចៅក្រមដែលចុះហត្ថលេខាយល់ឃើញថាសហព្រះរាជអាជ្ញាអន្តរជាតិបានមានហេតុផលដើម្បីជឿជាក់ថាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជូនដំ ណឹងទៅសហចៅក្រមស៊ើបអង្កេត ត្រូវបានប្រព្រឹត្តមិនត្រឹមតែនៅតាមទីកន្លែងនានាដែលមានលើក ឡើងយ៉ាងជាក់ច្បាស់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដូចជាទីតាំងភ្នំប្រុស និងគោកព្រីង ប៉ុណ្ណោះ គឺថែមទាំងនៅតាមទីតាំងដែលមានទំនាក់ទំនងគ្នាជាមូលដ្ឋានដែលត្រូវបានប្រទះឃើញនៅទួលបេង និងវត្តអង្គញដីដែលសហចៅក្រមស៊ើបអង្កេតមានភារកិច្ចស៊ើបអង្កេតទៀតផង។

61. ចៅក្រមដែលចុះហត្ថលេខា បន្ទាប់ពីពិនិត្យល្អិតល្អន់ទៅលើកិច្ចស៊ើបសួរដែលរងការជំទាស់ យល់ឃើញថាកិច្ចស៊ើបសួរទាំងនោះមិនលាតត្រដាងនូវអង្គហេតុថ្មីៗ ដែលតម្រូវឲ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ ស៊ើបសួរបន្ថែមឡើយ។ ប៉ុន្តែកិច្ចស៊ើបសួរទាំងនោះបង្ហាញអំពីភស្តុតាងដែលគ្រាន់តែបញ្ជាក់អះ អាង និងបញ្ជាក់លម្អិតអំពីកាលៈទេសៈនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ដែលត្រូវបានអនុវត្តក្រោមការគ្រប់គ្រងរបស់ [redacted] នៅស្រុកកំពង់សៀមប៉ុណ្ណោះ។ ពិសេសជាងនេះទៅទៀតនោះ កិច្ចស៊ើបសួរទាំងនេះបញ្ជាក់ការពិតអំពីការចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូន

---

ជំនួស, ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D107/16, ទំព័រ ១-២។ របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស, ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១១, ឯកសារ D3/23, ទំព័រ ១។

[100] *ដូចឯកសារយោងខាងលើ។*

រឿងឱ្យ ស៊ើបសួរដែលថាការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ពិតជាបានកើតឡើងជាលក្ខណៈប្រព័ន្ធនៅស្រុកកំពង់សៀម និងថាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅស្រុកកំពង់សៀម ពិតជាបានកើតឡើងក្រោមបញ្ជារបស់ [redacted][101]។ ទោះជាទីតាំង ទំហំ និងលក្ខណៈពិតប្រាកដនៃទីតាំងវត្ត អង្គញដី និងទួលបេង[102] និងសេចក្ដីលម្អិតនៃបញ្ជារបស់ [redacted][103] ត្រូវបានរក

---

[101] *សូមមើល ឧទាហរណ៍* ឯកសារ D117/71, ERN 01056221-01056232 (ភាសាអង់គ្លេស) ទំព័រ៨ ឬ ERN 01056228 ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣, ឆ៤៤។ សូមមើលផងដែរ កំណត់ហេតុស្ដាប់ចម្លើយ [redacted], ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D107/5, ERN 00787222-00787228 (ភាសាអង់គ្លេស) ទំព័រ ៦ ឬ ERN 00787227 ("[[redacted]] ជាអ្នកទទួលខុសត្រូវខាងចាប់ប្រជាជននៅក្នុងស្រុកកំពង់សៀម។ ខាងស្រុកមានកងឃោធាស្រុករបស់គាត់ដើម្បីចាប់ដែលមានមេបញ្ជាការឃោធាឈ្មោះ [redacted] [...]។ [...] [redacted] [...]ជាប្រធានសង្កាត់អង្គញដី។ មនុស្សទាំងអស់នោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់[redacted]")

[102] *សូមមើល ឧទាហរណ៍* កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted], ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៤, ឯកសារ D117/34, ERN 00967607-00967612 (ភាសាអង់គ្លេស) ទំព័រ ៤,៥ ឬ ERN 00967610-00967611 ("មន្ទីរសន្តិសុខនេះ [...] ស្ថិតនៅជិត [វត្ត] អង្គញដី។ [...] វាជាកន្លែងតូច [...] មានអ្នកទោសជាង១០នាក់")។ កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted], ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣, ឯកសារ D117/32, ERN 00966994-00967001(ភាសាអង់គ្លេស) ទំព័រ ៥ ឬ ERN 00966998 ("*នៅខាងឆ្វេងដៃ ជាទីតាំងមន្ទីរស្រុកកំពង់សៀមរបស់* [redacted] *ដែលមានចម្ងាយប្រហែល ២០០ ម៉ែត្រពីមន្ទីរឃុំក្រឡា ហើយបន្ទាប់ពីមន្ទីរស្រុកនោះ ជាទីតាំងរបស់មន្ទីរពេទ្យស្រុកដែលនៅខាងឆ្វេងដៃដូចគ្នា។ នៅឈៀងទល់មុខមន្ទីរពេទ្យស្រុកនោះជាទីតាំងវត្តអង្គញដី។ ហើយនៅជាប់វត្តអង្គញដីនោះ ជាទីតាំងមន្ទីរសន្តិសុខស្រុក [...]។ នៅខាងលិចវត្តនោះ គឺជាទីតាំងមន្ទីរសន្តិសុខស្រុកចាស់ស្ថិតនៅភូមិទួលបេង [...] កន្លែងនោះជាទីតាំងសម្លាប់មនុស្ស*")។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី [redacted], ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤, ឯកសារ D117/37, ERN 01072502-01072511 (ភាសាអង់គ្លេស) ទំព័រ ៨ ឬ ERN 01072509 (ទួលបេង [...] ខ្ញុំឃើញមានអណ្ដូងទឹកមួយ និងរណ្ដៅពីរដែលមានសាកសពពេញកំពុងហើម")។

[103] *សូមមើល ឧទាហរណ៍*កំណត់ហេតុនៃការស្ដាប់ចម្លើយ [redacted], ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥, ឯកសារ D117/71, ERN 01056221-01056232 (ភាសាអង់គ្លេស) ត្រង់ទំព័រ ៨-៩ ឬ ERN 01056228-01056229 ("ខ្ញុំជាលេខាស្រុកកំពង់សៀម។ [...] ក្នុងពេលប្រជុំប្រចាំខែ [redacted] បានបញ្ជាឱ្យខ្ញុំកំណត់អត្តសញ្ញាណប្រជា ជនចាម និងអតីតទាហាន លន់ នល់ ក្នុងឃុំនីមួយៗ។ [...] ខ្ញុំបានប្រជុំជាមួយគណៈឃុំឱ្យកំណត់អត្តសញ្ញាណ និងធ្វើបញ្ជីជនជាតិចាម និងអតីតទាហាន លន់ នល់ [...]។ [...] ក្រោយពេលខ្ញុំរាយការណ៍ទៅ[redacted] បញ្ជាមកខ្ញុំ ហើយខ្ញុំបានបញ្ជាឱ្យ [redacted] រៀបចំធ្វើការចាប់ខ្លួន។ មនុស្សត្រូវបានចាប់ខ្លួនពីមូលដ្ឋានបញ្ជូនទៅមន្ទីរស្រុក ហើយខ្ញុំបញ្ជូនពួកគេបន្តទៅសន្តិសុខតំបន់")។ កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី[redacted], ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤, ឯកសារ D191.1.112 (ឯកសារ D219/119.1.3), ERN 00797019-00797026 (ភាសាអង់គ្លេស) ទំព័រ ៣ ឬ ERN 00797021 ("[redacted] បានហៅយើងទៅប្រជុំ គាត់និយាយអំពីខ្មាំងក្នុងជួរអង្គការ។ ថាត្រូវវែកមុខពួកគេ ហើយត្រូវកម្ចាត់ខ្សែរយៈពួកគេ។ បើបងប្អូនត្រូវគេចាត់ទុកជាខ្មាំង គេនឹងយកគ្រួសារ

ឃើញតាមរយៈ កិច្ចស៊ើបសួរបន្ទាប់ពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏របកគំហើញទាំងនេះពុំមែនជាអង្គហេតុថ្មីដែលតម្រូវឱ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតបានទទួលដំណឹងរួចហើយអំពីអត្ថិភាពនៃគុកស្រុក និងទីតាំងសម្លាប់មនុស្សនៅស្រុកកំពង់សៀ ដែលទាក់ទងដោយផ្ទាល់ជាមួយទីតាំងភ្នំប្រុស និង គោកព្រីង។ ចៅក្រមដែលចុះហត្ថលេខា កត់សម្គាល់ឃើញថាតាមការពិតសក្ខីកម្មទាំងនេះ ជាភស្តុតាងដែលបញ្ជាក់បំភ្លឺអំពីកាលៈទេសៈដែលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ត្រូវបានប្រព្រឹត្ត និងដែលរួមចំណែកដល់ការកំណត់បទចោទ។

62. ហេតុដូច្នេះ ចៅក្រមដែលចុះហត្ថលេខា យល់ឃើញថាក្រោយពេលដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទួលបេង និងវត្តអង្គញជី ស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ និងហេតុដូច្នេះកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដែលទាក់ទងនឹងទីតាំងទីនោះ មុនថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ គឺពុំមែនកំហុសនីតិវិធីឡើយ។ អាស្រ័យហេតុនេះ ចៅក្រមដែលចុះហត្ថលេខា ពុំចាំបាច់ពិចារណាអំពីចំណោទថាតើកិច្ចស៊ើបសួរទាំងនោះបានរំលោភសិទ្ធិរបស់ [redacted] ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ឬបទចោទទាក់ទងនឹងទួលបេង មានកំហុសនីតិវិធីឬទេឡើយ។ ចៅក្រមដែលចុះហត្ថលេខាច្រានចោលពាក្យសុំឱ្យធ្វើមោឃភាពនេះ។

ភ្នំពេញថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

Judge Olivier BEAUVALLET

Judge Kang Jin BAIK

---

ទាំងមូលទៅ"). *សូមមើល ផងដែរ* កំណត់ហេតុស្តីពីការស្តាប់ចម្លើយ [redacted] ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D107/4, ERN 00787234-00787240 (ភាសាអង់គ្លេស) ទំព័រ ៣ ឬ ERN 00787236។ កំណត់ហេតុស្តាប់ចម្លើយ [redacted] ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២, ឯកសារ D107/5, ERN 00787222-00787228(ភាសាអង់គ្លេស) ទំព័រ ៦ ឬ ERN 00787227, កំណត់ហេតុស្តាប់ចម្លើយ [redacted] ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារ D107/7, ERN 00787211-00787216 (ភាសាអង់គ្លេស) ទំព័រ ៤ ឬ 00787214។